កុមាររៀន កុមារចេះ

# កូនខ្លែងអំនួត



កុមាររៀន
កុមារចេះ
ក ១២៣

# កូនខ្លែងអំនួត




និពន្ធដោយ ៖ **កញ្ញា កប វណ្ណហួច**

វិចិត្ររូបភាពដោយ ៖ **លោក ស៊ិន ធួកណា**

**កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង នៃក្រសួងអប់រំ យុវជន និងកីឡា**

ចំណងជើង ៖ **កូនខ្លែងអំនួត**
និពន្ធដោយ ៖ **កញ្ញា កប វណ្ណហួច**
កែសម្រួលដោយ ៖ **លោក ជូ ជីនិត**
វិចិត្ររូបភាពដោយ ៖ **លោក ស៊ិន ធួកណា**

សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយក្រោមអាជ្ញាប័ណ្ណ CC BY SA ។

សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីកុមាររៀនកុមារចេះ ដែលជាកម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីជំនួយពីពលរដ្ឋអាមេរិក។

ដើម្បីស្វែងរកសៀវភៅនេះនិងសៀវភៅដទៃទៀតសម្រាប់កុមារ លោកអ្នកអាចចូលទៅកាន់ទំព័រហ្វេសប៊ុកកុមាររៀនកុមារចេះ

www.facebook.com/123komar




ឬគេហទំព័រ តោះអាន ឬទាញយកកម្មវិធីបណ្ណាល័យឌីជីថលតោះអាន

Let's Read
www.LetsReadAsia.org

រដូវរំហើយមកដល់ ក្មេងៗលេងបង្ហោះខ្លែងយ៉ាងសប្បាយរីករាយ នៅតាមទីវាល។ កុមារាម្នាក់ កំពុងបង្ហោះខ្លែងឱ្យហើរឡើងខ្ពស់បន្តិចម្តងៗ។



ខ្លែងទាំងអស់សប្បាយណាស់ ព្រោះពួកគេបានហើររេរាំចុះឡើង តាមកម្លាំងខ្យល់បក់។ ដោយឡែកកូនខ្លែងមួយ មានមោទកភាពជាងគេក្នុងចំណោមខ្លែងទាំងអស់។

អស្ចារ្យមែន! ខ្ញុំអាចហើរបានខ្ពស់ជាងគេ។ ទេសភាពទីនេះស្អាតណាស់។ មើលចុះ! មនុស្ស ដើមឈើ ផ្ទះ និងអ្វីៗដែលនៅខាងក្រោម គឺមានទំហំតូចៗជាងខ្ញុំទាំងអស់។



បន្តិចក្រោយមក ចាបមួយគូ ក៏ហើរមកជិតកូនខ្លែងនោះ។ ឃើញដូចនេះ កូនខ្លែងក៏កើតចិត្តច្រណែន។ វាបាននិយាយទៅកាន់ចាបទាំងពីរ រួចក៏ប្រឹងទាញបន្លាយខ្សែដើម្បីហើរឡើងឱ្យខ្ពស់ជាងចាប។



នៅពេលហើរបានខ្ពស់បន្តិច យន្តហោះចំណាស់មួយ ហោះ
សំដៅមកក្បែរវា។ កូនខ្លែងក៏សួរ៖



ចៅអាចហើរបានដោយសារខ្សែ និងកម្លាំងខ្យល់បក់តែប៉ុណ្ណោះ ចំណែកតាអាចហោះបាន ដោយសារកម្លាំងម៉ាស៊ីន។

និយាយរួច តាយន្តហោះ ក៏ហោះចេញហួសឆ្ងាយទៅ។



ខ្លែងក៏គិតចង់យកឈ្នះតាយន្តហោះ។ វាចាប់ផ្ដើមគ្រវីខ្លួនបញ្ច្រាសខ្យល់។ ខ្សែខ្លែងក៏រលាអស់ ហើយតឹងទៅៗ។ ទីបំផុត ខ្សែខ្លែងក៏ដាច់។



កូនខ្លែងសប្បាយចិត្តណាស់ ព្រោះវាអាចហោះហើរតាមខ្យល់ដោយសេរី។ វាហើរខ្ពស់ជាងបក្សី អាចប៉ះដុំពពកធំៗ ហើយវាខំហើរតាមតាយន្តហោះ។





ពេលកូនខ្លែងហើរទៅមុខបានឆ្ងាយ
បន្តិច ខ្យល់ក៏ចាប់ផ្ដើមស្ងប់។ កូនខ្លែង
ក៏ធ្លាក់ចុះមកវិញបន្តិចម្ដងៗ។ វាភ័យ
ណាស់ ទោះបីជាវាខំព្យាយាមយ៉ាងណា
ក៏វាមិនអាចហើរឡើងទៅលើខ្ពស់វិញ
បានដែរ។





កូនខ្លែងក៏រសាត់ឆ្ងាយទៅៗ ហើយក៏ធ្លាក់ចុះទៅក្នុងព្រៃ។
កូនខ្លែងទើរលើមែកឈើ កម្រើកខ្លួនមិនរួច។



ពេលខ្យល់បក់មកបន្តិច ខ្លែងប្រឹងហើរឡើងយ៉ាងលំបាក ប៉ុន្តែ វាបានត្រឹមផ្លាស់ទីពីមែកឈើមួយទៅមែកឈើមួយប៉ុណ្ណោះ។ ខ្លែងក៏យំដោយអស់សង្ឃឹម។



ពេលនោះ ចាបទាំងពីរក៏មកទំសម្រាកលើមែកឈើជិតកូនខ្លែង។ វាក៏សុំឱ្យចាបទាំងពីរជួយ។ ចាបប្រឹងទាញកូនខ្លែងចេញពីមែកឈើបាន ប៉ុន្តែដោយខ្លែងធ្ងន់ពេកមិនអាចហើរបាន។ «ពួកយើងខ្លួនតូចណាស់ មិនអាចជួយឯងបានទេ ទាល់តែឯងមានស្លាបដូចយើងទើបអាចហើរទៅគ្រប់កន្លែងដែលឯងចង់ទៅបាន។ យើងដល់ពេលទៅសំបុកវិញហើយ។» ថារួចចាបក៏ហើរចេញបាត់ទៅ។



រំពេចនោះ ស្រាប់តែលាន់ឮសន្ធឹកខ្យល់យ៉ាងខ្លាំងសំដៅវា។ នោះគឺតាយន្តហោះ។





ខ្លែងខំប្រឹងហើរតាមកម្លាំងខ្យល់ពីក្រោយតាយន្តហោះ។

វាខំហើរចេញផុតពីចុងឈើ ហើយក៏ហើរកាត់បឹងធំមួយ។

តាយន្តហោះក៏ចេញហួសបាត់ទៅ។ កូនខ្លែងខំប្រឹងត្រដរហើរឡើងដើម្បីឱ្យផុតបឹងធំនោះ ប៉ុន្តែកម្លាំងខ្យល់បក់ក៏ថយចុះបន្តិចម្តងៗ។ កូនខ្លែងក៏ធ្លាក់ចុះ ដោយវាខំបិទភ្នែក និងអស់សង្ឃឹមជាថ្មី។



ភ្លាមនោះ ចាបទាំងពីរក៏ពាំកន្ទុយវាឡើង ប៉ុន្តែកូនខ្លែងនៅតែបន្តធ្លាក់ចុះ។ សំណាងល្អ ខ្យល់កួចមួយវិប បាននាំយកវាឡើងទៅលើវិញ។ ខ្លែងក៏ខំប្រឹងសំកាំងទប់ខ្លួន ហើយបណ្ដោយខ្លួនឱ្យទៅតាមកម្លាំងខ្យល់បក់ ដើម្បីឱ្យផុតពីបឹងដ៏ធំធេងនោះ។



ទីបំផុតវាក៏ធ្លាក់ចុះម្តងទៀត ហើយទើរលើរបងផ្ទះមួយ។ ពេលនោះ កុមារាម្នាក់ក៏ស្ទុះចេញពីផ្ទះមករើសវា។ កូនខ្លែងរំភើបចិត្តណាស់ ចំណែកឯកុមារម្ចាស់ខ្លែងក៏ត្រេកអរណាស់ដែរ។



ស្អែកឡើង កុមារាក៏ចងភ្ជាប់ខ្សែខ្លែងជាថ្មី ហើយបង្ហើរខ្លែងលេងម្តងទៀត។ កូនខ្លែងរីករាយជាខ្លាំងដែលបានហើរម្តងទៀត។ វាបានជួបចាប និងតាយន្តហោះជាថ្មីម្តងទៀត។



## ពន្យល់ពាក្យ

| | | |
|---|---|---|
| មោទកភាព | (ន.) | សេចក្ដីត្រេកអរខ្លាំងហួសប្រមាណ |
| អស្ចារ្យ | (គុ.) | ដែលគួរឱ្យស្ងើចសរសើរក្រៃពេក |
| បន្លាយ | (កិ.) | បណ្ដោយឱ្យកាន់តែវែង |
| អំនួត | (ន.) | ការនិយាយអួត |
| សំកាំង | (កិ.) | ឈប់ទ្រឹងនឹងនៅមួយស្របក់ |

## សំណួរត្រិះរិះ

១. ហេតុអ្វីបានជាកូនខ្លែងចង់ហើរឱ្យបានកាន់តែខ្ពស់?

២. តើហេតុការណ៍អ្វីខ្លះបានកើតឡើងចំពោះកូនខ្លែងពេលដែលវាហើរបានខ្ពស់ជាងគេ?

៣. ក្រោយពីធ្លាក់ចូលក្នុងព្រៃ តើកូនខ្លែងអាចមកជួបម្ចាស់វិញដោយសារអ្វី?

៤. បើប្អូនជាកូនខ្លែង តើចំណុចអ្វីខ្លះដែលប្អូនគួររៀនសូត្រតាម និងមិនគួររៀនសូត្រតាម?

សម្រាប់ថ្នាក់ទី៣



កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង
នៃក្រសួងអប់រំ យុវជន និងកីឡា

9 789924 560593

បោះពុម្ពឆ្នាំ២០២៣